ក្រសួងធម្មការនិងសាសនា





# បទបង្ហាញ

# ស្តីពី

# សៀវភៅថវិកាសង្ខេបឆ្នាំ២០២៦

# របស់ក្រសួងធម្មការនិងសាសនា

# មាតិកា

១.ចក្ខុវិស័យនិងបេសកកម្មរបស់ក្រសួងធម្មការនិងសាសនា

២.អាទិភាពគោលនយោបាយ/សកម្មភាពការងារសំខាន់ៗនៅក្នុងឆ្នាំ២០២៦

៣.រចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួងធម្មការនិងសាសនា

៤.ថវិកាតាមកម្មវិធី/អនុកម្មវិធីនីមួយៗ ក្នុងឆ្នាំ២០២៦

៥.សូចនាករសមិទ្ធកម្មគន្លឹះតាមកម្មវិធីនីមួយៗ

៦.សេចក្តីសន្និដ្ឋាន

# ១.ចក្ខុវិស័យនិងបេសកកម្មរបស់ក្រសួងធម្មការនិងសាសនា

## ១.១. ចក្ខុវិស័យ

- ចក្ខុវិស័យរបស់ក្រសួងធម្មការនិងសាសនា គឺការលើកកម្ពស់សាសនារបស់រដ្ឋ ការលើកកម្ពស់សីលធម៌សង្គម ការរក្សាសុខដុមនីយកម្មសាសនា ការពង្រឹងគុណភាពអប់រំពុទ្ធិកសិក្សាគ្រប់កម្រិត ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស។

## ១.២. បេសកកម្ម

- ក្រសួងធម្មការនិងសាសនា បំពេញបេសកកម្មជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការដឹកនាំនិងគ្រប់គ្រងវិស័យធម្មការនិងសាសនានៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការអប់រំពុទ្ធិកសិក្សា ការសិក្សាស្រាវជ្រាវពាក់ព័ន្ធនិងវប្បធម៌ អក្សរសាស្ត្រ ប្រពៃណី និងវប្បធម៌ ទំនៀមទម្លាប់ និងការបោះពុម្ពផ្សាយនានាដែលទំនាក់ទំនងនិងសាសនា។

# ២.អាទិភាពគោលនយោបាយ/សកម្មភាពការងារសំខាន់ៗ នៅក្នុងឆ្នាំ២០២៦

- យោងតាមអនុក្រឹត្យលេខ១៥៤ អនក្រ.បក និងផែនការយុទ្ធសាស្ត្រ ក្រសួងធម្មការ និងសាសនា មានតួនាទី ភារកិច្ច និងសកម្មភាពការងារសំខាន់ៗ ដូចខាងក្រោម៖

## ២.១. ការលើកកម្ពស់សាសនារបស់រដ្ឋ

- បន្តនិងពន្លឿនរៀបចំសេចក្តីព្រាងច្បាប់ស្តីពីជំនឿសាសនា
- បន្តលើកតម្កើងតម្លៃព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ
- រៀបចំក្រុមជំនុំព្រះត្រៃបិដកខ្មែរឡើងវិញ
- រៀបចំបទដ្ឋានក្រមប្រតិបត្តិស្តីពីប្រព័ន្ធសង្ឃាភិបាល
- រៀបចំក្រមប្រតិបត្តិស្តីពីការអនុវត្តសង្ឃប្រកាសនៃអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស

# ២.អាទិភាពគោលនយោបាយ/សកម្មភាពការងារសំខាន់ៗ នៅក្នុងឆ្នាំ២០២៦

## ២.១. ការលើកកម្ពស់សាសនារបស់រដ្ឋ

- សិក្សារៀបចំរចនាប័ទ្មសំណង់សាសនា
- រៀបចំចងក្រងទម្រង់ពុម្ពគំរូព្រះពុទ្ធបដិមាខ្មែរ
- សិក្សាក្នុងការរៀបចំគោលការណ៍ណែនាំស្តីពីការបំបួសកុលបុត្រក្នុងព្រះពុទ្ធសាសនា
- សិក្សានិងរៀបចំគោលការណ៍ណែនាំស្តីពីការបង្កើតសមាគមអាចារ្យខ្មែរ
- សិក្សារៀបចំនីតិវិធីរួមស្តីពីកិច្ចគាំពារសង្គមតាមវិស័យសាសនា
- រៀបចំនីតិវិធី និងយន្តការនៃការចងក្រងប្រវត្តិវត្តអារាម
- រៀបចំគោលការណ៍ណែនាំស្តីពីទស្សនាទានព្រះពុទ្ធសាសនា
- សិក្សារៀបចំផែនការជាតិស្តីពីការអភិវឌ្ឍវត្តអារាមប្រកបដោយចីរភាព
- បន្តការទប់ស្កាត់ការយកសាសនាទៅធ្វើអាជីវកម្មនិងបង្កជាវិបត្តិសាសនា

# ២.អាទិភាពគោលនយោបាយ/សកម្មភាពការងារសំខាន់ៗ នៅក្នុងឆ្នាំ២០២៦

## ២.២. ការលើកកម្ពស់សីលធម៌សង្គម

- បន្តរៀបចំកម្មវិធីនាទីពុទ្ធសាសនាផ្សារភ្ជាប់សង្គមនៅស្ថាប័នរដ្ឋ ឯកជន និង សាលារៀន
- បន្តផលិតវីដេអូអប់រំខ្លីៗ ស្តីពីសីលធម៌សង្គម និងកម្មវិធីបុណ្យផ្សេងៗ ដើម្បីធ្វើការចាក់ផ្សាយនៅតាមបណ្តា រាជធានី ខេត្ត បណ្តាញទំនាក់ទំនងសង្គម និងបណ្តាញសារព័ត៌មានផ្សេងៗ
- សិក្សារៀបចំឯកសារបណ្តុះបណ្តាលស្តីពីសាសនពិធីតាមទំនៀមខ្មែរ
- សិក្សាចងក្រងស្តីពីព្រះរាជជីវប្រវត្តិ និងព្រះជីវប្រវត្តិ សម្តេចព្រះមហាសង្ឃរាជ និងសម្តេចគណៈសង្ឃនាយក
- បន្តចងក្រងនិងបោះពុម្ពសៀវភៅស្តីពីទំនៀមទម្លាប់ ប្រពៃណី និងសាសនា

# ២.អាទិភាពគោលនយោបាយ/សកម្មភាពការងារសំខាន់ៗ នៅក្នុងឆ្នាំ២០២៦

## ២.២. ការលើកកម្ពស់សីលធម៌សង្គម

- សិក្សារៀបចំនីតិវិធីរួមស្តីពីការពង្រឹងសីលធម៌សង្គមតាមសាសនមាគ៌ា
- បន្តការរៀបចំការអប់រំសីលធម៌សង្គម ដល់យុវជននៅតាមសាលារៀន និងមណ្ឌលកែប្រែ
- រៀបចំនីតិវិធីនៃការគ្រប់គ្រងស្ថានីយផ្សព្វផ្សាយព្រះធម៌តាមទូរទស្សន៍និងវិទ្យុ
- បង្កើនការអប់រំតាមរយៈសាសនាដល់ស្រទាប់យុវជន និងកុមារឱ្យយល់ដឹងច្បាស់ពីតម្លៃដ៏វិសេសវិសាលនៃវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ដែលជាអត្តសញ្ញាណរបស់ជាតិ
- បន្តរៀបចំនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់សង្គមនិងវគ្គបណ្តុះបណ្តាលស្តីពី តួនាទីភារកិច្ច និងក្រមសីលធម៌អាចារ្យខ្មែរ

# ២. អាទិភាពគោលនយោបាយ/សកម្មភាពការងារសំខាន់ៗ នៅក្នុងឆ្នាំ២០២៦

## ២.៣. ការរក្សាសុខដុមនីយកម្មសាសនា

- បន្តជំរុញការរៀបចំវេទិកាកិច្ចសន្ទនាអន្តរជំនឿ
- សិក្សារៀបចំនីតិវិធីរួមស្តីពីកិច្ចសន្ទនាអន្តរជំនឿសាសនានៅកម្ពុជា
- រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃអង្គការសមាគមក្នុងវិស័យសាសនា នៅកម្ពុជា
- រៀបចំគោលនយោបាយជាតិស្តីពីសុខដុមនីយកម្មសាសនានៅកម្ពុជា
- រៀបចំគោលនយោបាយជាតិស្តីពីការគ្រប់គ្រងវិស័យពាហិរសាសនានៅកម្ពុជា
- ដោះស្រាយអធិករណ៍ក្នុងជួរសាសនានានាឱ្យបានទាន់ពេលវេលានិងទប់ស្កាត់មិនឱ្យកើតមានឡើងនូវអធិករណ៍ អន្តរសាសនា

# ២. អាទិភាពគោលនយោបាយ/សកម្មភាពការងារសំខាន់ៗ នៅក្នុងឆ្នាំ២០២៦

## ២.៤. ការពង្រីកគុណភាពវិស័យពុទ្ធិកសិក្សាគ្រប់កម្រិត

- បន្តអភិវឌ្ឍវិស័យពុទ្ធិកសិក្សាទាំងបីកម្រិតនិងជំរុញឱ្យការបណ្ដុះបណ្ដាលស្រប តាមស្តង់ដារ អប់រំជាតិ និងអន្តរជាតិ
- បន្តពង្រឹងគុណភាពសិក្សានិងការអប់រំពុទ្ធិកសិក្សាគ្រប់កម្រិត
- បន្តរៀបចំវគ្គបណ្ដុះបណ្ដាលវិក្រឹត្យការគ្រូគ្រប់កម្រិតសិក្សា
- បន្តរៀបចំបច្ចេកទេសសិក្សាតាមប្រព័ន្ធឌីជីថល

# ២. អាទិភាពគោលនយោបាយ/សកម្មភាពការងារសំខាន់ៗ នៅក្នុងឆ្នាំ២០២៦

## ២.៤. ការពង្រឹងគុណភាពវិស័យពុទ្ធិកសិក្សាគ្រប់កម្រិត

- បន្តអភិវឌ្ឍវិស័យពុទ្ធិកសិក្សាទាំងបីកម្រិតនិងជំរុញឱ្យការបណ្ដុះបណ្ដាលស្រប
- ២.៥. ការអភិវឌ្ឍសមត្ថភាពស្ថាប័ននិងធនធានមនុស្ស
- ពង្រឹងគុណភាពប្រព័ន្ធគ្រប់គ្រងផែនការអភិវឌ្ឍវិស័យធម្មការនិងសាសនា
- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាកម្មវិធី
- បង្កើនប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងរដ្ឋបាល បរិវត្តកម្មឌីជីថល និងយេនឌ័រ។

# ៣. រចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួងធម្មការនិងសាសនា

## ៣.១. ការរៀបចំកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព

- ដើម្បីសម្រេចឱ្យបានគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធម្មការនិងសាសនា ២០២៤-២០២៨ ខាងលើទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងឆ្នាំ២០២៦ ក្រសួងធម្មការនិងសាសនា ដាក់ចេញនូវកម្មវិធីចំនួន៣ អនុកម្មវិធីចំនួន១១ និងចង្កោមសកម្មភាពចំនួន៩៨ ។

**តារាងទី១៖ សង្ខេបចំនួនកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព**

| ឈ្មោះកម្មវិធី | អនុកម្មវិធី | ចង្កោមសកម្មភាព |
|---|---|---|
| កម្មវិធីទី១៖ ការរក្សាសុខដុមនីយកម្មសាសនា | ៤ | ៣២ |
| កម្មវិធីទី២៖ ការអប់រំវិស័យពុទ្ធិកសិក្សា | ៣ | ៣៣ |
| កម្មវិធីទី៣៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ | ៣ | ៣៣ |

# ៣. រចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួងធម្មការនិងសាសនា

## ៣.២. គោលបំណងកម្មវិធី

លើកស្ទួយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ និងលើកកម្ពស់ តម្លៃសីលធម៌សង្គម តាមរយៈសាសនា ព្រមទាំងគោរពសេរីភាពខាងជំនឿសាសនា ដើម្បីរក្សាឱ្យបាននូវសុខដុមនីយកម្មសាសនា ចូលរួមចំណែក ការពារ ថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម។



កម្មវិធីទី១៖ ការរក្សាសុខដុមនីយកម្មសាសនា

លើកកម្ពស់ចំណេះដឹងផ្នែកពុទ្ធចក្រ និងអាណាចក្រក្នុងការកសាងធនធានមនុស្សប្រកបដោយសមត្ថភាព សីលធម៌ និងចរិយាធម៌។



កម្មវិធីទី២៖ ការអប់រំវិស័យពុទ្ធិកសិក្សា

កសាងរដ្ឋបាលសាធារណៈ ដែលមានសមត្ថភាពខ្ពស់ ខ្លាំងវៃឆ្លាត និងស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាជន។



កម្មវិធីទី៣៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

# ៤.ថវិកាតាមកម្មវិធី/អនុកម្មវិធីនីមួយៗ ក្នុងឆ្នាំ២០២៦

## ៤.១. ជនជានថវិកាឆ្នាំ២០២៦

- ក្រសួងបានទទួលថវិកាវិភាជន៍ពីរាជរដ្ឋាភិបាលក្នុងឆ្នាំ២០២៦ មានថវិកាសរុបចំនួន **៧៧ ៣៥៩.៥ លានរៀល** ដើម្បីអនុវត្តកម្មវិធីចំនួន៣ រួមមាន៖

  ១. រក្សាសុខដុមនីយកម្មសាសនា

  ២. ការអប់រំវិស័យពុទ្ធិកសិក្សា និង

  ៣. ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ។

# ៤.ថវិកាតាមកម្មវិធី/អនុកម្មវិធីនីមួយៗ ក្នុងឆ្នាំ២០២៦

## រូបភាពទី១៖ ថវិកាក្រសួងតាមកម្មវិធី

*(ឯកតា៖ លានរៀល)*



# ៤.ថវិកាតាមកម្មវិធី/អនុកម្មវិធីនីមួយៗ ក្នុងឆ្នាំ២០២៦

## តារាងទី២៖ គម្រោងថវិកាចំណាយតាមកម្មវិធី និងអនុកម្មវិធី

(ឯកតា៖ លានរៀល)

| សរុបថវិការួមឆ្នាំ២០២៦ | 77,359.5 |
|---|---|
| **កម្មវិធីទី១៖ ការរក្សាសុខដុមនីយកម្មសាសនា** | **9,125.8** |
| អនុកម្មវិធីទី១.១៖ ការថែរក្សាគុណតម្លៃព្រះពុទ្ធសាសនា | 4,361.0 |
| អនុកម្មវិធី១.២៖ ការស្រាវជ្រាវ ចងក្រង អភិរក្ស និងផ្សព្វផ្សាយឯកសារប្រពៃណីទំនៀមទម្លាប់ វប្បធម៌សាសនា | 208.4 |
| អនុកម្មវិធីទី១.៣៖ ការលើកកម្ពស់សេរីភាពខាងជំនឿ សាសនា ប្រកបដោយសុខដុមនីយកម្ម | 305.4 |
| អនុកម្មវិធីទី១.៤៖ សេវាគាំទ្រការរក្សាសុខដុមនីយកម្មសាសនា របស់មន្ទីរជំនាញរាជធានី ខេត្ត | 4,251.0 |
| **កម្មវិធីទី២៖ ការអប់រំវិស័យពុទ្ធិកសិក្សា** | **36,116.1** |
| អនុកម្មវិធីទី២.១៖ ការអប់រំពុទ្ធិកសិក្សាគ្រប់កម្រិត | 2,034.7 |
| អនុកម្មវិធីទី២.២៖ ការផ្តល់សេវាទ្រទ្រង់វិស័យពុទ្ធិកសិក្សា | 13,423.7 |
| អនុកម្មវិធីទី២.៣៖ សេវាគាំទ្រការអប់រំវិស័យពុទ្ធិកសិក្សា របស់មន្ទីរជំនាញរាជធានី ខេត្ត | 20,657.7 |
| **កម្មវិធីទី៣៖ ការគ្រប់គ្រងស្ថាប័ននិងសេវាគាំទ្រទូទៅ** | **32,117.6** |
| អនុកម្មវិធីទី៣.១៖ ការផ្តល់សេវាគាំទ្រទូទៅ | 12,458.9 |
| អនុកម្មវិធីទី៣.២៖ កិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងកិច្ចការនីតិកម្ម | 297.4 |
| អនុកម្មវិធីទី៣.៣៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុង | 113.3 |
| អនុកម្មវិធីទី៣.៤៖ សេវាគាំទ្រការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅរបស់មន្ទីរជំនាញរាជធានី ខេត្ត | 19,248.0 |

# ៤.ថវិកាតាមកម្មវិធី/អនុកម្មវិធីនីមួយៗ ក្នុងឆ្នាំ២០២៦

## រូបភាពទី២៖ ថវិកាកម្មវិធីទី១ ការរក្សាសុខដុមនីយកម្មសាសនា

*(ឯកតា៖ លានរៀល)*



# ៤.ថវិកាតាមកម្មវិធី/អនុកម្មវិធីនីមួយៗ ក្នុងឆ្នាំ២០២៦

## រូបថតទី១៖ សកម្មភាពសំខាន់ៗ របស់កម្មវិធីទី១






# ៤.ថវិកាតាមកម្មវិធី/អនុកម្មវិធីនីមួយៗ ក្នុងឆ្នាំ២០២៦

## រូបភាពទី៣៖ ថវិកាកម្មវិធីទី២ ការអប់រំវិស័យពុទ្ធិកសិក្សា

*(ឯកតា៖ លានរៀល)*



# ៤.ថវិកាតាមកម្មវិធី/អនុកម្មវិធីនីមួយៗ ក្នុងឆ្នាំ២០២៦

## រូបថតទី២៖ សកម្មភាពសំខាន់ៗ របស់កម្មវិធីទី២



# ៤.ថវិកាតាមកម្មវិធី/អនុកម្មវិធីនីមួយៗ ក្នុងឆ្នាំ២០២៦

## រូបភាពទី៤៖ ថវិកាកម្មវិធីទី៣ ការគ្រប់គ្រងស្ថាប័ននិងសេវាគាំទ្រទូទៅ

(ឯកតា៖ លានរៀល)



# ៤.ថវិកាតាមកម្មវិធី/អនុកម្មវិធីនីមួយៗ ក្នុងឆ្នាំ២០២៦

## រូបថតទី៣៖ សកម្មភាពសំខាន់ៗ របស់កម្មវិធីទី៣









# ៥.សូចនាករសមិទ្ធកម្មគន្លឹះតាមកម្មវិធីនីមួយៗ

## សូចនាករសមិទ្ធកម្មរបស់ក្រសួងធម្មការនិងសាសនា ឆ្នាំ២០២៦ (ជាភាគរយ)

| ក្រសួង៖<br>ធម្មការនិងសាសនា | កម្មវិធីទី១៖<br>ការរក្សាសុខដុមនីយកម្មសាសនា | អង្គភាពទទួលបន្ទុក៖<br>អគ្គនាយកដ្ឋានកិច្ចការសាសនា | កាលបរិច្ឆេទ៖<br>៣០/០៤/២០២៥ |
|---|---|---|---|
| **គោលបំណងនៃកម្មវិធី៖** លើកស្ទួយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋនិងលើកកម្ពស់ តម្លៃសីលធម៌សង្គមតាមរយៈសាសនា ព្រមទាំងគោរពសេរីភាពខាងជំនឿសាសនា ដើម្បីរក្សាឱ្យបាននូវសុខដុមនីយកម្មសាសនា ចូលរួមចំណែក ការពារ ថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម។ | | | |
| **ប្រភេទសូចនាករ៖** សូចនាករលទ្ធផលចុងក្រោយ | | **លេខកូដសូចនាករ៖** PI 1-02 | |
| **ឈ្មោះសូចនាករវែង៖** ចំនួនព្រះសង្ឃ អាចារ្យ អាចារិនី ពុទ្ធបរិស័ទ បានទទួលការបណ្តុះបណ្តាលតួនាទីភារកិច្ច និងពង្រឹងសមត្ថភាពការគ្រប់គ្រងប្រកបដោយចីរភាព | | | |
| **ឈ្មោះសូចនាករខ្លី៖** ចំនួនព្រះសង្ឃ អាចារ្យ អាចារិនី ពុទ្ធបរិស័ទ បានទទួលការបណ្តុះបណ្តាលប្រកបដោយជោគជ័យប្រចាំឆ្នាំ | | | |
| **គោលបំណងសារៈសំខាន់នៃសូចនាករ៖** ដើម្បីធ្វើការវាស់វែងទៅលើការអនុវត្តន៍តួនាទី ភារកិច្ច និងសមត្ថភាពនៃការគ្រប់គ្រង ដឹកនាំរបស់សិក្ខាកាមដែលទទួលបានការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ | | | |
| **សេចក្តីពណ៌នា៖** ការបើកវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយគោលធម៌វិន័យសាសនា និងច្បាប់ ព្រមទាំងលិខិតបទដ្ឋាននានារបស់ប្រទេស ចំពោះមេដឹកនាំសាសនា និងសាសនិកឱ្យបានយល់ដឹងហើយរួមគ្នាអនុវត្ត ដើម្បីរក្បាននូវសុខដុមនីយកម្មសាសនា និងការគ្រប់គ្រងវិស័យធម្មការនិងសាសនាប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភា | | | |
| **ការគណនា៖** ចំនួនព្រះសង្ឃ អាចារ្យ អាចារិនី ពុទ្ធបរិស័ទ បានទទួលការបណ្តុះបណ្តាលប្រកបដោយជោគជ័យធៀបទៅនឹងផែនការដែលបានគ្រោង។ | | | |
| **ប្រភពទិន្នន័យ៖** របាយការណ៍ទទួលបានពីនាយកដ្ឋានក្រោមឱវាទនៃអគ្គនាយកដ្ឋានកិច្ចការសាសនា។ | | | |
| **ថ្ងៃកំណត់នៃទិន្នន័យ៖** នៅខែកុម្ភៈ នៃឆ្នាំថវិកា (N+1) | | | |
| **កាលបរិច្ឆេទកែប្រែចុងក្រោយ៖** | | | |

# ៥.សូចនាករសមិទ្ធកម្មគន្លឹះតាមកម្មវិធីនីមួយៗ

## សូចនាករសមិទ្ធកម្មរបស់ក្រសួងធម្មការនិងសាសនា ឆ្នាំ២០២៦ (ជាភាគរយ)

| ក្រសួង៖ ធម្មការនិងសាសនា | កម្មវិធីទី២៖ ការអប់រំវិស័យពុទ្ធិកសិក្សា | អង្គភាពទទួលបន្ទុក៖ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ | កាលបរិច្ឆេទ៖ ៣០/០៤/២០២៥ |
|---|---|---|---|

**គោលបំណងកម្មវិធី៖** លើកកម្ពស់ចំណេះដឹងផ្នែកពុទ្ធចក្រ និងអាណាចក្រក្នុងការកសាងធនធានមនុស្សប្រកបដោយសមត្ថភាព សីលធម៌ និងចរិយាធម៌។

| | |
|---|---|
| ប្រភេទសូចនាករ៖<br>☐ សូចនាករលទ្ធផលចុងក្រោយ<br>☐ សូចនាករលទ្ធផលក្នុងឆ្នាំ | លេខកូដសូចនាករ៖ PI 2-01 |

**ឈ្មោះសូចនាករវែង៖** ភាគរយសមណសិស្ស-និស្សិត និងសិស្ស-និស្សិតដែលបានបញ្ចប់ការសិក្សាគ្រប់កម្រិត

**ឈ្មោះសូចនាករខ្លី៖** ភាគរយសមណសិស្ស-និស្សិត និងសិស្ស-និស្សិតដែលបានបញ្ចប់ការសិក្សាគ្រប់កម្រិត

**គោលបំណង/ សារៈសំខាន់នៃសូចនាករ៖**
ក-ដើម្បីធ្វើការវាស់វែងពីប្រសិទ្ធភាពនៃការទទួលបានការសិក្សាដោយជោគជ័យ របស់សមណសិស្ស-និស្សិត និងសិស្ស-និស្សិតគ្រប់កម្រិត។
ខ-ដើម្បីធ្វើការវាស់វែងអំពីប្រសិទ្ធភាពនៃការអប់រំវិស័យពុទ្ធិកសិក្សា

**សេចក្តីពណ៌នា៖** ភាគរយខ្ពស់ នៃការទទួលបានជោគជ័យក្នុងការសិក្សារបស់ សមណសិស្ស-និស្សិត និងសិស្ស-និស្សិត បង្ហាញពីប្រសិទ្ធភាព នៃការអប់រំពុទ្ធិកសិក្សា និងធនធានមនុស្សប្រកបដោយគុណភាព ដែលបានចូលរួមលើកកម្ពស់វិស័យព្រះពុទ្ធសាសនានៅកម្ពុជា

**ការគណនា៖** ចំនួនសមណសិស្ស-និស្សិត និងសិស្ស-និស្សិត ដែលបានប្រឡងជាប់ធៀបនឹងសមណសិស្ស-សិស្ស និងសមណនិស្សិត-និស្សិត ដែលបានចូលរួមប្រឡង

**ប្រភពទិន្នន័យ៖** របាយការណ៍ប្រឡងប្រចាំឆ្នាំក្នុងវិស័យពុទ្ធិកសិក្សាដែលជាទិន្នន័យកត់ត្រាផ្ទាល់របស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

**ថ្ងៃកំណត់នៃទិន្នន័យ៖** នៅរៀងរាល់ការបញ្ចប់ឆ្នាំសិក្សាពុទ្ធិកសិក្សា

**កាលបរិច្ឆេទកែប្រែចុងក្រោយ៖**

# ៥.សូចនាករសមិទ្ធកម្មគន្លឹះតាមកម្មវិធីនីមួយៗ

## សូចនាករសមិទ្ធកម្មរបស់ក្រសួងធម្មការនិងសាសនា ឆ្នាំ២០២៦ (ជាចំនួន)

| ក្រសួង៖<br>ធម្មការនិងសាសនា | កម្មវិធីទី២៖<br>ការអប់រំវិស័យពុទ្ធិកសិក្សា | អង្គភាពទទួលបន្ទុក៖<br>អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ | កាលបរិច្ឆេទ៖<br>៣០/០៤/២០២៥ |
|---|---|---|---|
| គោលបំណងកម្មវិធី៖ លើកកម្ពស់ចំណេះដឹងផ្នែកពុទ្ធចក្រ និងអាណាចក្រក្នុងការកសាងធនធានមនុស្សប្រកបដោយសមត្ថភាព សីលធម៌ និងចរិយាធម៌។ | | | |
| ប្រភេទសូចនាករ៖<br>☐ សូចនាករលទ្ធផលចុងក្រោយ<br>☐ សូចនាករលទ្ធផលក្នុងឆ្នាំ | | លេខកូដសូចនាករ៖ PI 2-02 | |
| ឈ្មោះសូចនាករវែង៖ ចំនួនសមណសិស្ស-និស្សិតនិងសិស្ស-និស្សិតបានទទួលការអប់រំគ្រប់កម្រិត | | | |
| ឈ្មោះសូចនាករខ្លី៖ ចំនួនសមណសិស្ស-និស្សិតនិងសិស្ស-និស្សិតបានទទួលការអប់រំគ្រប់កម្រិត | | | |
| គោលបំណង/ សារៈសំខាន់នៃសូចនាករ៖ដើម្បីធ្វើការវាស់វែងពីចំនួនសមណសិស្ស-និស្សិត និងសិស្ស-និស្សិត ដែលបានទទួលការអប់រំក្នុងរយៈពេលនៃឆ្នាំសិក្សាពុទ្ធិកសិក្សា។ | | | |
| សេចក្តីពណ៌នា៖ ចំនួននៃសមណសិស្ស-និស្សិត និងសិស្ស-និស្សិត ដែលបានទទួលការអប់រំក្នុងពុទ្ធិកសិក្សាគ្រប់កម្រិតនិងធនធានមនុស្សប្រកបដោយចំណេះដឹង គុណភាព ដែលបានចូលរួមលើកកម្ពស់វិស័យព្រះពុទ្ធសាសនានៅកម្ពុជា | | | |
| ការគណនា៖ ចំនួននៃសមណសិស្ស-និស្សិត និងសិស្ស-និស្សិត ដែលបានអប់រំឆ្នាំសិក្សាធៀបនិងសមណសិស្ស-សិស្ស និងសមណនិស្សិត-និស្សិតដែលគ្រោងក្នុងផែនការ។ | | | |
| ប្រភពទិន្នន័យ៖ របាយការណ៍ទទួលបានចំនួនសមណសិស្ស-និស្សិត និងសិស្ស-និស្សិត អប់រំតាមសាលាពុទ្ធិកសិក្សាប្រចាំឆ្នាំក្នុងវិស័យពុទ្ធិកសិក្សា។ | | | |
| ថ្ងៃកំណត់នៃទិន្នន័យ៖ នៅរៀងរាល់ឆមាសទី១ ឆ្នាំសិក្សាពុទ្ធិកសិក្សា | | | |
| កាលបរិច្ឆេទកែប្រែចុងក្រោយ៖ | | | |

# ៥.សូចនាករសមិទ្ធកម្មគន្លឹះតាមកម្មវិធីនីមួយៗ

## សូចនាករសមិទ្ធកម្មរបស់ក្រសួងធម្មការនិងសាសនា ឆ្នាំ២០២៦ (ជាភាគរយ)

| ក្រសួង៖ ធម្មការនិងសាសនា | កម្មវិធីទី៣៖ ការគ្រប់គ្រងស្ថាប័ននិងសេវាគាំទ្រទូទៅ | អង្គភាពទទួលបន្ទុក៖ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | កាលបរិច្ឆេទ៖ ៣០/០៤/២០២៥ |
|---|---|---|---|
| គោលបំណងកម្មវិធី៖ ដើម្បីកសាងរដ្ឋបាលសាធារណៈដែលមានសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាជន។ | | | |
| ប្រភេទសូចនាករ៖ សូចនាករលទ្ធផលក្នុងឆ្នាំ | | លេខកូដសូចនាករ៖ PI 3-02 | |
| ឈ្មោះសូចនាករវែង ៖ ភាពទាន់ពេលវេលានៃការផ្តល់សេវារដ្ឋបាល និងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព | | | |
| ឈ្មោះសូចនាករខ្លី ៖ ភាពទាន់ពេលវេលានៃការផ្តល់សេវារដ្ឋបាល និងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព | | | |
| គោលបំណង/សារៈសំខាន់នៃសូចនាករ៖ ដើម្បីផ្តល់សេវាគាំទ្រទូទៅឱ្យទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព | | | |
| សេចក្តីពណ៌នា៖ ការផ្តល់សេវាគាំទ្រទូទៅឱ្យទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព ដើម្បីអភិវឌ្ឍន៍ស្ថាប័ន | | | |
| ការគណនា៖ | | | |
| ប្រភពទិន្នន័យ៖ | | | |
| ថ្ងៃកំណត់នៃទិន្នន័យ៖ | | | |
| កាលបរិច្ឆេទកែប្រែចុងក្រោយ៖ | | | |

# ៥.សូចនាករសមិទ្ធកម្មគន្លឹះតាមកម្មវិធីនីមួយៗ

## សូចនាករសមិទ្ធកម្មរបស់ក្រសួងធម្មការនិងសាសនា ឆ្នាំ២០២៦ (ជាភាគរយ)

| ក្រសួង៖<br>ធម្មការនិងសាសនា | កម្មវិធីទី៣៖<br>ការគ្រប់គ្រងស្ថាប័ននិងសេវាគាំទ្រទូទៅ | អង្គភាពទទួលបន្ទុក៖<br>អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | កាលបរិច្ឆេទ៖<br>៣០/០៤/២០២៥ |
|---|---|---|---|
| គោលបំណងកម្មវិធីទី៣៖ ដើម្បីកសាងរដ្ឋបាលសាធារណៈដែលមានសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាជន។ | | | |
| ប្រភេទសូចនាករ ៖ សូចនាករលទ្ធផលក្នុងឆ្នាំ | | លេខកូដសូចនាករ៖ PI 3-01 | |
| ឈ្មោះសូចនាករវែង ៖ ចំនួនរចនាសម្ព័ន្ធអង្គភាព ដើម្បីគាំទ្រស្ថាប័ន | | | |
| ឈ្មោះសូចនាករខ្លី ៖ ចំនួនរចនាសម្ព័ន្ធអង្គភាព ដើម្បីគាំទ្រស្ថាប័ន | | | |
| គោលបំណង/សារៈសំខាន់នៃសូចនាករ៖<br>ក. ដើម្បីធ្វើការកែសម្រួល និងវិភាគមុខងាររចនាសម្ព័ន្ធស្ថាប័ន<br>ខ. ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងស្ថាប័ន | | | |
| សេចក្តីពណ៌នា៖ ចំនួនអង្គភាពត្រូវបានកែសម្រួល និងឱ្យស្របទៅតាមលិខិតបទដ្ឋានគតិយុត្តរបស់ស្ថាប័ន | | | |
| ការគណនា៖ | | | |
| ប្រភពទិន្នន័យ៖ | | | |
| ថ្ងៃកំណត់នៃទិន្នន័យ៖ | | | |

# ៦.សេចក្តីសន្និដ្ឋាន

- ថវិកាឆ្នាំ២០២៦ របស់ក្រសួងធម្មការនិងសាសនា ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធម្មការនិងសាសនាឆ្នាំ ២០២៤-២០២៨ ស្របតាម "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១" របស់រាជរដ្ឋាភិបាល។ ជាមួយនឹងកញ្ចប់ថវិកានេះ ក្រសួងធម្មការនិងសាសនានឹងបន្តផ្តល់សេវាសាធារណៈសម្រាប់អ្នកទទួលផលរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។
- ថវិកាឆ្នាំ២០២៦ នឹងបន្តផ្តល់អាទិភាពលើការផ្តល់សេវាសាធារណៈសម្រាប់អ្នកទទួលផលស្របតាម គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តិដែលមានស្រាប់ ដូចជា៖ ផ្តល់កិច្ចគាំពារសង្គមតាមវិស័យសាសនា ផ្តល់ការអប់រំតាមរយៈសាសនាដល់ស្រទាប់យុវជន និងកុមារឱ្យយល់ដឹងច្បាស់ពីតម្លៃដ៏វិសេសវិសាលនៃវប្បធម៌ប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ដែលជាអត្តសញ្ញាណរបស់ជាតិ ចុះបញ្ជីនិងផ្តល់ទិដ្ឋាការសមាគម និងអង្គការដែលមានចរិតសាសនា ដោះស្រាយអធិករណ៍ក្នុងជួរសាសនានានាឱ្យបានទាន់ពេលវេលា និងទប់ស្កាត់មិនឱ្យកើតមានឡើងនូវអធិករណ៍អន្តរសាសនា និងផ្តល់ការបណ្តុះបណ្តាលវិស័យពុទ្ធិកសិក្សា។